# មហាកបិជាតក




*ព្រះសាស្តា កាលភិក្ខុទាំងឡាយពោលទោសទេវទត្ត ដែលប្រកបនាយខ្មាន់ធ្នូ និងប្រមៀលថ្មក្នុងកាលជាក្រោយ បានត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះទេ សូម្បីក្នុងកាលមុន ទេវទត្តក៏ប្រមៀលថ្មលើតថាគតដែរ ហើយទ្រង់នាំអតីតនិទានមកថា ៖*

*ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ។ នៅក្នុងកាសិកគ្រាម មានកស្សកព្រាហ្មណ៍ (អ្នកស្រែ) មួយក្ជួររាស់ រួចដោះគោចេញ ប្រារព្ធនឹងធ្វើការកាប់គាស់ ។ គោទាំងឡាយកាលស៊ីស្មៅកឈើ ត្រង់គុម្ពឈើមួយ បានរត់ចូលទៅកាន់*

ព្រៃតាមលំដាប់ ។ កសិករព្រាហ្មណ៍កំណត់វេលាហើយ ដាក់ចុះការកាប់គាស់ រួចសម្លឹងរកមើលគោ មិនបានឃើញ គាត់ដល់សេចក្តីទោមនស្ស កាលស្វែងរកគោទាំងនោះ ក៏ចូលទៅក្នុងព្រៃ ដើររហូតដល់ព្រៃហិមពាន្ត ។ ព្រាហ្មណ៍នោះវង្វេងទិសក្នុងព្រៃនោះ អត់អាហារត្រាច់ទៅ អស់ ៧ ថ្ងៃ ឃើញដើមទន្លាប់មួយដើម ហើយឡើងបេះផ្លែបរិភោគ ភ្លាត់ធ្លាក់ពីដើមទន្លាប់ ចូលទៅក្នុងរណ្តៅដែលមានជម្រៅ ៦០ ហត្ថ ។ ព្រាហ្មណ៍ធ្លាក់ក្នុងរណ្តៅនោះកន្លងទៅអស់ ១០ ថ្ងៃ ។

ក្នុងសម័យនោះ ព្រះពោធិសត្វកើតក្នុងកំណើតសត្វស្វា កាលកំពុងបរិភោគផលាផល ក៏បានឃើញបុរសនោះ ទើបចង់ខ្សែនឹងថ្ម ជួយបុរសនោះឡើងមក ដាក់ឲ្យអង្គុយលើដុំថ្ម ហើយពោលយ៉ាងនេះថា នែព្រាហ្មណ៍ដ៏ចម្រើន យើងហត់លំបាកណាស់ យើងនឹងដេកមួយភ្លេត អ្នកចូររក្សាយើងផង ។ ព្រាហ្មណ៍នោះយកដុំថ្មមកគប់ស្វាពោធិសត្វដែលកំពុងដេកលក់ ។ ព្រះមហាសត្វបានដឹងទង្វើរបស់ព្រាហ្មណ៍ ហើយក៏ឡើងទៅអង្គុយលើមែកឈើ រួចពោលថា នែបុរសដ៏ចម្រើន អ្នកចូរដើរលើដីចុះ យើងនឹងទៅហើយប្រាប់ផ្លូវអ្នកដោយចុងមែកឈើ ។ ព្រះពោធិសត្វនាំបុរសនោះចេញពីព្រៃ រហូតដល់ផ្លូវ (មនុស្ស) រួចក៏ចូលទៅកាន់ដើងភ្នំវិញ ។ បុរសនោះប្រទូស្តព្រះមហាសត្វហើយ ក៏កើតឃ្លង់ ទៅជាមនុស្សប្រេត ក្នុងពេលបច្ចុប្បន្នទាន់ភ្នែក ។

បុរសនោះត្រូវសេចក្តីទុក្ខបៀតបៀនអស់ ៧ ឆ្នាំ ត្រាច់ចូលទៅក្នុងឧទ្យានឈ្មោះ **មិគាជិនៈ** ក្នុងនគរពារាណសី គាត់ក្រាលស្លឹកចេក ខាងក្នុងកំពែង ដេកសោយទុក្ខវេទនា ។ ក្នុងពេលនោះ ព្រះបាទពារាណសីយាងទៅកាន់ឧទ្យាន ត្រាច់ទៅក្នុងទីនោះ ទតឃើញបុរសនោះ ហើយសួរថា អ្នកជាអ្វី អ្នកធ្វើអំពើអ្វី បានជាដល់សេចក្តីទុក្ខដូច្នេះ ។ បុរសនោះប្រាប់រឿងរ៉ាវទាំងអស់ដោយពិស្តារដល់ព្រះរាជា ។

ព្រះសាស្តាកាលប្រកាសសេចក្តីនោះ ទើបត្រាស់ថា

ពារាណស្យំ អហូ រាជា, កាសីនំ រដ្ឋវឌ្ឍនោ;
មិត្តាមច្ចបរិព្យូឡ្ហោ, អគមាសិ មិគាជិនំ។

*ព្រះរាជាក្នុងក្រុងពារាណសី ព្រះអង្គញ៉ាំងដែន របស់ពួកជនអ្នកដែនកាសីឲ្យចម្រើន ព្រះអង្គមានពួកមិត្ត និងអាមាត្យហែហមហើយស្ដេចទៅកាន់មិគាជិនឧទ្យាន ។*

តត្ថ ព្រាហ្មណមទ្ទក្ខិ, សេតំ ចិត្រំ កិលាសិនំ;
វិទ្ធស្តំ កោវិឡារំវ, កិសំ ធមនិសន្ថតំ។

*បានទតឃើញព្រាហ្មណ៍ម្នាក់ កើតឃ្លង់ស ឃ្លង់ពពាល កើតស្រែង មានសាច់លៀនចេញ ដូចជាផ្ការលួសផ្អុង ស្គមឡើងសរសៃរវាម ក្នុងមិគាជិនឧទ្យាននោះ។*

បរមការុញ្ញតំ បត្តំ, ទិស្វា កិច្ចគតំ នរំ;
អវច ព្យម្ហិតោ រាជា, យក្ខានំ កតមោ នុសិ។

*ព្រះរាជាទ្រង់ទតឃើញ ជនមានសេចក្ដីលំបាក ដល់នូវភាពគួរអាណិតក្រៃលែង ទ្រង់ស្ញើប ទ្រង់ត្រាស់សួរថា បណ្ដាពួកយក្ស អ្នកជាយក្សអ្វី ។*

ហត្ថបាទា ច តេ សេតា, តតោ សេតតរំ សិរោ;
គត្តំ កម្មាសវណ្ណំ តេ, កិលាសពហុលោ ចសិ។

*ដៃនិងជើងរបស់អ្នកសផង ក្បាលរបស់អ្នកសលើសជាងដៃ និងជើងនោះផង ខ្លួនរបស់អ្នក មានសម្បុរពព្រុះផង មានស្រែងដ៏ច្រើនផង ។*

វដ្ដនាវឡិសង្កាសា, បិដ្ឋិ តេ និន្នតុន្នតា;
កាឡបព្ពាវ តេ អង្គា, នាញ្ញំ បស្សាមិ ឯទិសំ។

*ខ្នងរបស់អ្នករេងិបរេងុប ដូចជាល្ងួសដែលវេញផង អវយវៈរបស់អ្នក ដូចវល្លិលែនពែនផង យើងមិនដែលឃើញបុគ្គលដទៃបែបនេះឡើយ ។*

ឧគ្ឃដ្ឋចានោ តសិតោ, កិសោ ធមនិសន្ថតោ;
ឆាតោ អាតត្តរូបោសិ, កុតោសិ កត្ថ គច្ឆសិ។

*អ្នកមានជើងប្រឡាក់ដោយធូលី ជាអ្នកតក់ស្លុត ស្គម ឡើងសរសៃរវាម ស្រេកឃ្លាន មានសភាពជាអ្នកមិនឆ្អែត តើអ្នកមកអំពីទីណា នឹងទៅក្នុងទីណា។*

ទុទ្ទសី អប្បការោសិ, ទុព្ពណ្ណោ ភីមទស្សនោ;
ជនេត្តិ យាបិ តេ មាតា, ន តំ ឥច្ឆេយ្យ បស្សិតុំ។

*អ្នកជាបុគ្គលលំបាកមើល មិនមានទ្រង់ទ្រាយ មានសម្បុរមិនល្អ មើលទៅគួរខ្លាច សូម្បីតែមាតាបង្កើតរបស់អ្នក ក៏មិនចង់ឃើញអ្នកដែរ ។*

កឹ កម្មមការំ បុព្វេ, កំ អវជ្ឈំ អឃាតយិ;
កិព្ពិសំ យំ ករិត្វាន, ឥទំ ទុក្ខំ ឧបាគមិ។

*អ្នកបានធ្វើនូវអំពើដូចម្តេចក្នុងកាលមុន អ្នកបានបៀតបៀននូវសត្វ ដែលមិនគួរសម្លាប់ដូចម្តេច អ្នកធ្វើនូវអំពើអាក្រក់ណា ក៏បាននូវសេចក្តីទុក្ខនេះ ។*

*លំដាប់នោះ ព្រាហ្មណ៍ពោលថា*

តគ្ឃ តេ អហមក្ខិស្សំ, យថាបិ កុសលោ តថា;
សច្ចវាទិញ្ហិ លោកស្មិំ, បសំសន្តីធ បណ្ឌិតា។

*បើដូច្នោះ អ្នកឃ្លាសវៃ (និយាយ) យ៉ាងណា ទូលព្រះបង្គំជាខ្ញុំនឹងទូលយ៉ាងនោះ ព្រោះថា ក្នុងលោកនេះ អ្នកប្រាជ្ញាទាំងឡាយ តែងសរសើរបុគ្គលអ្នកនិយាយពាក្យពិត ។*

ឯកោ ចរំ គោគវេសោ, មូឡ្ហោ អច្ចសរិំ វនេ;
អរញ្ញេ ឥរីណេ វិវនេ, នានាកុញ្ជរសេវិតេ។

*ទូលព្រះបង្គំជាខ្ញុំតែម្នាក់ឯង កាលដើរកគោ ក៏វង្វេងដើរចូលទៅក្នុងព្រៃសូន្យសុង ជាព្រៃដាច់ទឹក ព្រៃស្ងាត់ឈឹង ដែលពួកដំរីផ្សេងៗ នៅហើយ ។*

វាឡមិគានុចរិតេ, វិប្បនដ្ឋោស្មិ កាននេ;
អចរិំ តត្ថ សត្តាហំ, ខុប្បិបាសសមប្បិតោ។

*ទូលព្រះបង្គំជាខ្ញុំ វង្វេងនូវផ្លូវក្នុងព្រៃ ដែលពួកម្រឹគកាចដើរទៅមក ជាអ្នកមានសេចក្ដីស្រេកឃ្លាន អស់ ៧ ថ្ងៃ ដើរទៅក្នុងព្រៃនោះ ។*

តត្ថ តិន្ទុកមទ្ទក្ខិំ, វិសមដ្ឋំ ពុភុក្ខិតោ;
បបាតមភិលម្ពន្តំ, សម្បន្នផលធារិនិំ។

*ទូលព្រះបង្គំជាខ្ញុំ ត្រូវសេចក្ដីឃ្លានគ្របសង្កត់ ក៏បានឃើញដើមទម្លាប់ក្នុងព្រៃនោះ ដុះនៅក្នុងទីមិនស្មើ សំយុងទៅកាន់ជ្រោះ ជាឈើទ្រទ្រង់នូវផ្លែមានរសផ្អែម ។*

វាតស្សិតានិ ភក្ខេសិំ, តានិ រុច្ចិំសុ មេ ភុសំ;
អតិត្តោ រុក្ខមារុយ្ហិំ, តត្ថ ហេស្សាមិ អាសិតោ។

*ទូលព្រះបង្គំ ជាខ្ញុំ បានទទួលទានផ្លែឈើទាំងឡាយ ដែលខ្យល់បក់ធ្លាក់ចុះមក ផ្លែឈើទាំងនោះ ពេញចិត្តទូលព្រះបង្គំជាខ្ញុំយ៉ាងក្រៃលែង ទូលព្រះបង្គំជាខ្ញុំមិនឆ្អែត ក៏ឡើងលើដើមដោយគិតថានឹងស៊ីឲ្យឆ្អែតស្កប់ស្កល់លើដើមនោះ។*

ឯកំ មេ ភក្ខិតំ អាសិ, ទុតិយំ អភិបត្ថិតំ;
តតោ សា ភញ្ជថ សាខា, ឆិន្នា ផរសុនា វិយ។

*ទូលព្រះបង្គំជាខ្ញុំ ទទួលទានផ្លែទម្លាប់មួយហើយ ប្រាថ្នាផ្លែជាគម្រប់ពីរទៀត លំដាប់នោះ មែកឈើនោះ ក៏បាក់ហាក់ដូចជាគេកាប់នឹងប៉ូវថៅ ។*

សោហំ សហាវ សាខាហិ, ឧទ្ធំបាទោ អវំសិរោ;
អប្បតិដ្ឋេ អនាលម្ពេ, គិរិទុគ្គស្មិ បាបតំ។

*ទូលព្រះបង្គំជាខ្ញុំនោះ ក៏ជាប់មកជាមួយនឹងមែកឈើ មានជើងឡើងលើ មានក្បាលចុះក្រោម ធ្លាក់ចុះទៅក្នុងជ្រោះភ្នំ ដែលមិនមានទីឈរ មិនមានទីតោង ។*

យស្មា ច វារិ គម្ភីរំ, តស្មា ន សមបជ្ជិសំ;
តត្ថ សេសឹ និរានន្ទោ, អនូនា ទស រត្តិយោ។

*ទឹកជ្រៅ មានត្រឹមណា ទូលព្រះបង្គំជាខ្ញុំមិនធ្លាក់ដល់ធ្លាក់ដល់ត្រឹមណោះទេ មិនមានសេចក្ដីត្រេកអរ មិនមានទីពឹង ដេកក្នុងជ្រោះនោះអស់ ១០ រាត្រីគត់ ។*

អថេត្ថ កបិ មាគញ្ឆិ, គោនង្គុលោ ទរីចរោ;
សាខាហិ សាខំ វិចរន្តោ, ខាទមានោ ទុមប្ផលំ។

*គ្រានោះ ស្វាមានកន្ទុយ ដូចជាកន្ទុយគោ ត្រេចទៅតាមជ្រោះភ្នំ មកដល់ទីនោះ លោតពីមែកមួយ ទៅកាន់មែកមួយ បានស៊ីនូវផ្លែឈើ ។*

សោ មំ ទិស្វា កិសំ បណ្ឌុំ, ការុញ្ញមការំ មយិ;
អម្ភោ កោ នាម សោ ឯត្ថ, ឯវំ ទុក្ខេន អដ្ដិតោ។

ស្វានោះបានឃើញនូវទូលព្រះបង្គំជាខ្ញុំ ដែលស្គមស្ទេកស្ទាំង ក៏ធ្វើនូវសេចក្ដីករុណា ចំពោះទូលព្រះបង្គំជាខ្ញុំ រួចសួរថា ម្នាលអ្នកដ៏ចម្រើន អ្នកឯងជាអ្វីនេះជាអ្វី ត្រូវទុក្ខគ្របសង្កត់ ក្នុងទីនេះយ៉ាងនេះ ។

មនុស្សោ អមនុស្សោ វា, អត្តានំ មេ បវេទយ;
តស្សញ្ជលិំ បណាមេត្វា, ឥទំ វចនមព្រវិ។

អ្នកជាមនុស្ស ឬមិនមែនមនុស្ស ចូរប្រាប់ខ្លួនដល់យើង ទូលព្រះបង្គំជាខ្ញុំ ក៏ប្រណម្យ អញ្ជលីចំពោះស្វានោះ ហើយពោលនូវពាក្យនេះថា

មនុស្សោហំ ព្យសម្បត្តោ, សា មេ នត្ថិ ឥតោ គតិ;
តំ វោ វទាមិ ភទ្ទំ វោ, ត្វញ្ច មេ សរណំ ភវ។

ខ្ញុំជាមនុស្សដល់នូវអំណាចនៃ (សេចក្ដីវិនាស) ខ្ញុំទៅអំពីទីនេះមិនបានទេ ព្រោះហេតុនោះ ខ្ញុំជម្រាបអ្នក សូមសេចក្ដីចម្រើន មានដល់អ្នក សូមអ្នកជាទីពឹងរបស់ខ្ញុំ ។

គរុំ សិលំ គហេត្វាន, វិចរី បព្ពតេ កបិ;
សិលាយ យោគ្គំ កត្វាន, និសភោ ឯតទព្រវិ។

ស្វាដ៏ប្រសើរ ត្រាច់ទៅលើភ្នំ ក៏យកនូវថ្មដ៏ធ្ងន់ ចងខ្សែនឹងថ្ម ហើយពោលនូវពាក្យនេះថា

ឯហិ មេ បិដ្ឋិមារុយ្ហ, គីវំ គណ្ហាហិ ពាហុភិ;
អហំ តំ ឧទ្ធរិស្សាមិ, គិរិទុគ្គត វេគសា។

អ្នកចូរមក ចូរឡើងជិះខ្នងខ្ញុំ ហើយតោងកខ្ញុំដោយដៃទាំងពីរ ខ្ញុំនឹងស្រង់អ្នកចាកជ្រោះភ្នំ ដោយកម្លាំង ។

តស្ស តំ វចនំ សុត្វា, រាជរិទ្ធស្ស សិរីមតោ;
បិដ្ឋិមារុយ្ហ ជីវស្ស, គីវំ ពាហាហិ អគ្គហឹ។

*ទូលព្រះបង្គំជាខ្ញុំ បានឮពាក្យស្តេចស្វាដ៏មានសិរីនោះ ក៏ឡើងជិះខ្នង នៃស្វាជាអ្នកប្រាជ្ញ ហើយតោងក ដោយដៃទាំងពីរ ។*

សោ មំ តតោ សមុដ្ឋាសិ, តេជស្សី ពលវា កបិ;
វិហញ្ញមានោ កិច្ឆេន, គិរិទុគ្គត វេគសា។

*ស្វានោះ មានតេជះមានកម្លាំង នឿយហត់ ដោយសេចក្តីលំបាក បានស្រង់ទូលព្រះបង្គំជាខ្ញុំចាកជ្រោះភ្នំ ដោយរហ័ស ។*

ឧទ្ធរិត្វាន មំ សណ្តោ, និសកោ ឯតទព្រវិ;
ត្វញ្ច មំ សម្ម រក្ខស្សុ, បសុបិស្សំ មុហុត្តកំ។

*ស្វាជាសប្បុរសដ៏ប្រសើរ លុះស្រង់ទូលព្រះបង្គំជាខ្ញុំរួចហើយ ក៏ពោលនូវពាក្យនេះថា នៃសម្លាញ់ អ្នកចូររក្សានូវខ្ញុំផង ខ្ញុំនឹងសម្រាកមួយរំពេច ។*

សីហា ព្យគ្ឃា ច ទីបី ច, អច្ឆកោកតរច្ឆយោ;
តេ មំ បមត្តំ ហឹសេយ្យុំ, តេ ត្វំ ទិស្វា និវារយ។

*បើពួកសត្វរាជសីហ៍ក្តី ពួកខ្លាធំក្តី ពួកខ្លាដំបងក្តី ពួកខ្លាឃ្មុំក្តី ពួកឆ្កែព្រៃក្តី ពួកខ្លាវខិនក្តី ពួកសត្វកាចទាំងនោះ មកបៀតបៀនខ្ញុំដែលធ្វេសប្រហែសហើយ បើអ្នកឃើញនូវសត្វ សាហាវទាំងនោះ ចូររារាំងផង ។*

ឯវំ មេ បរិត្តាតូន, បសុបី សោ មុហុត្តកំ;
តទាហំ ចាបិកំ ទិដ្ឋឹ, បដិលច្ឆឹ អយោនិសោ។

*ស្វានោះ ត្រូវទូលព្រះបង្គំជាខ្ញុំការពារយ៉ាងនេះ ហើយក៏ដេកលក់មួយស្របក់ទៅ គ្រានោះទូលព្រះបង្គំជាខ្ញុំ បានទិដ្ឋិក៏លាមក ដោយមិនត្រូវទំនងថា*

ភក្ខោ អយំ មនុស្សានំ, យថា ចញ្ញេ វនេ មិគា;
យំ នូនិមំ វធិត្វាន, ឆាតោ ខាទេយ្យ វានរិ។

*ស្វានេះ ជាអាហាររបស់ពួកមនុស្ស ដូចពួកម្រឹគដទៃ ក្នុងព្រៃដែរ បើដូច្នោះ អាត្មាអញឃ្លានហើយ គប្បីសម្លាប់នូវស្វានេះស៊ី ។*

អសិតោ ច គមិស្សាមិ, មំសមាទាយ សម្ពលំ;
កន្តារំ និត្ថរិស្សាមិ, បាថេយ្យំ មេ ភវិស្សតិ។

*អញស៊ីហើយ នឹងយកសាច់ ជាស្បៀងដើរទៅនឹងឆ្លងផ្លូវឆ្ងាយ ស្បៀងអញក៏មានស្រាប់ ។*

តតោ សិលំ គហេត្វាន, មត្ថកំ សន្និតាឡយិំ;
មម គត្តកិលន្តស្ស, បហារោ ទុព្ពលោ អហុ។

*លំដាប់នោះទូលព្រះបង្គំជាខ្ញុំ ចាប់យកដុំថ្មគប់ក្បាល (ស្វានោះ) កាលទូលព្រះបង្គំជាខ្ញុំ លំបាកដោយបាយ ការប្រហារ ក៏មានកម្លាំងថយ ។*

សោ ច វេគេនុទប្បត្តោ, កបិ រុហិរមក្ខិតោ;
អស្សុបុណ្ណេហិ នេត្តេហិ, រោទន្តោ មំ ឧទិក្ខតិ។

*ឯស្វានោះ ក៏ស្ទុះក្រោកឡើងដោយរហ័ស ប្រឡាក់ដោយឈាម មានភ្នែកពេញដោយទឹកភ្នែក យំសម្លឹងមើលទូលព្រះបង្គំជាខ្ញុំ ។*

មាយ្យោ មំ ករិ កន្ទន្តេ, ត្វញ្ច ជាមេតិសំ ករិ;
ត្វញ្ច ខោ ជាម ឥឃាវុ, អញ្ញេ វារេតុមរហសិ។

*រួចនិយាយថា បពិត្រអ្នកដ៏ចម្រើន អ្នកជាម្ចាស់ កុំធ្វើបាបខ្ញុំឡើយ អ្នកឯងធ្វើអំពើអាក្រក់បែបនេះ ម្នាលអ្នកដ៏មានអាយុវែង អ្នកឯងគួរតែហាមឃាត់នូវពួកសត្វដទៃ ។*

អហោ វត រេ បុរិស, តាវទុក្ករការក;
ឯទិសា វិសមា ទុគ្គា, បចាតា ឧទ្ធតោ មយា។

*យីអើហ្ន៎ នៃបុរសចង្រៃ ជាមនុស្សធ្វើអំពើអាក្រក់ដល់ម្ល៉េះ អញបានស្រង់ឯងឲ្យរួចពីជ្រោះស្រឡូងបែបនេះ ។*

អានីតោ បរលោកាវ, ទុព្ភេយ្យំ មំ អមញ្ញថ;
តំ តេន ចាបកាម្មេន, ចាបំ ចាបេន ចិន្តិតំ។

*អញនាំអ្នកឯងមក (នេះ) ដូចជានាំមកពីបរលោក អ្នកឯងសំគាល់យើងថា គួរប្រទូស្ត អំពើដ៏លាមកនោះ អ្នកឯងនោះជា មនុស្សលាមក ជាមនុស្សបាប គិតហើយ ។*

មា ហេវ ត្វំ អធម្មដ្ឋ, វេទនំ កដុកំ ផុសិ;
មា ហេវ ចាបកម្មំ តំ, ផលំ វេឡុំវ តំ វធិ។

*នៃអ្នកមិនឋិតនៅក្នុងធម៌ អ្នកឯងកុំប៉ះពាល់នូវទុក្ខវេទនា ដ៏ខ្លោចផ្សាឡើយ អំពើដ៏លាមកនោះ កុំសម្លាប់អ្នកឯងដូចជាផ្លែឫស្សី ដែលសម្លាប់ដើមឯងវិញឡើយ ។*

តយិ មេ នត្ថិ វិស្សាសោ, ចាបធម្ម អសញ្ញត;
ឯហិ មេ បិដ្ឋិតោ គច្ឆ, ទិស្សមានោវ សន្តិកេ។

*នៃអ្នកជា មនុស្សមានធម៌ដ៏លាមក មិនសង្រួម យើងលែងមានសេចក្ដីទុកចិត្តចំពោះអ្នក អ្នកឯងចូរមក អ្នកឯងចូរមានសរីរៈប្រាកដក្នុងទីជិត ដើរតាមក្រោយ យើងចុះ ។*

មុត្តោសិ ហត្ថា វាឡានំ, បត្តោសិ មានុសឹ បទំ;
ឯស មគ្គោ អជម្ហជ្ជ, តេន គច្ឆ យថាសុខំ។

*អ្នកឯងរួចផុតពីកណ្ដាប់ដៃនៃពួកម្រឹកកាចហើយ អ្នកឯងបានដល់ឧបចារៈជារបស់នៃមនុស្សហើយ នៃអ្នកមិនឋិតនៅក្នុងធម៌ នុ៎ះផ្លូវអ្នកឯង ចូរដើរទៅឲ្យសុខសប្បាយនោះចុះ ។*

ឥទំ វត្វា គិរិចរោ, រហាទេ បក្ខល្យ មត្ថកំ;
អស្សូនិ សម្បមជ្ជិត្វា, តតោ បព្ពតមារុហិ។

*ស្វាដែលត្រាច់ទៅលើភ្នំ លុះបានពោលពាក្យនេះហើយ ទើបលាងឈាមក្បាលរបស់ខ្លួន ហើយជូតទឹកភ្នែក ឲ្យជ្រះ លំដាប់នោះ ក៏លោតឡើងទៅលើភ្នំ ។*

សោហំ តេជាកិសន្តោស្មិ, បរិឡាហេន អដ្ដិតោ;
ឧយ្ហមានេន គត្តេន, វារឹ ចាតុំ ឧទាគមឹ។

*ទូលព្រះបង្គំជាខ្ញុំនោះ ជាបុគ្គលដែលស្វានោះផ្ដាសាហើយ ត្រូវសេចក្ដីក្ដៅក្រហាយបៀតបៀន មានខ្លួនក្ដៅអន្ទះអន្ទែង បានចូលទៅរកទទួលទានទឹក ។*

អគ្គិជា វិយ សន្តត្តោ, រហាទោ រុហិរមក្ខិតោ;
បុព្ពលោហិតសង្កាសោ, សព្ពោ មេ សមបជ្ជថ។

*អន្លង់ទឹងទាំងអស់ ក៏ក្ដៅសព្វ ហាក់ដូចជាភ្លើងឆេះ ជាអន្លង់ហាក់ដូចជាប្រឡាក់ឈាមហាក់ ដូចជាខ្ទុះនិងឈាម ប្រាកដកដល់ខ្ញុំ ។*

យាវន្តោ ឧទពិន្ទូនិ, កាយស្មឹ និបតឹសុ មេ;
តាវន្តោ គណ្ឌា ជាយេថ, អទ្ធពេលុវសាទិសា។

*ដំណក់ទឹកមានចំនួនប៉ុន្មាន ស្រក់លើកាយរបស់ទូលព្រះបង្គំជាខ្ញុំ បូសមានចំនួនប៉ុណ្ណោះ ប្រាកដស្មើដោយផ្លែក្នោមួយចំហៀង ក៏កើតឡើង ។*

បភិន្នា បគ្ឃរឹសុ មេ, កុណបា បុព្វលោហិតា;
យេន យេនេវ គច្ឆាមិ, គាមេសុ និគមេសុ ច។

*ទូលព្រះបង្គំជាខ្ញុំ ទៅក្នុងស្រុកនិងនិគមទាំងឡាយ តាមផ្លូវណាៗ បូសទាំងឡាយក៏បែកធ្លាយ ខ្ទុះនិងឈាមដ៏ស្អុយ ហូរចេញ ( ពីសរីរៈ ) របស់ទូលព្រះបង្គំជាខ្ញុំ ( តាមផ្លូវនោះ ) ។*

ទណ្ឌហត្ថា និវារេន្តិ, ឥត្ថិយោ បុរិសា ច មំ;
ឱក្កិតា បូតិគន្ធេន, មាស្សុ ឱរេន អាគមា។

*ពួកស្ត្រីនិងបុរស មានដំបងក្នុងដៃ ដែលត្រូវក្លិនស្អុយគ្របសង្កត់ហើយ ឃាត់ទូលព្រះបង្គំជាខ្ញុំថា អ្នកឯងកុំចូលមកខាងអាយឡើយ ។*

ឯតាទិសំ ឥទំ ទុក្ខំ, សត្ត វស្សានិ ទានិ មេ;
អនុភោមិ សកំ កម្មំ, បុព្វេ ទុក្កដមត្តនោ។

*សេចក្តីទុក្ខលំបាកនេះ ប្រាកដដូច្នេះ មានដល់ទូលព្រះបង្គំជាខ្ញុំ អស់ ៧ ឆ្នាំហើយមកដល់ឥឡូវនេះ ទូលព្រះបង្គំជាខ្ញុំ នៅតែទទួលរងនូវកម្មជារបស់ខ្លួន ដែលខ្លួនធ្វើអាក្រក់ហើយក្នុងកាលមុន ។*

តំ វោ វទាមិ ភទ្ទន្តេ, យាវន្តេត្ថ សមាគតា;
មាស្សុ មិត្តាន ទុព្ភិត្ថោ, មិត្តទុព្ភោ ហិ បាបកោ។

*ព្រោះហេតុនោះ ទូលព្រះបង្គំជាខ្ញុំ សូមក្រាបបង្គំទូលចំពោះព្រះអង្គ សូមសេចក្តីចម្រើនមានដល់ព្រះអង្គ ពួកអ្នកដែលមកជួបជុំគ្នាក្នុងទីនេះ សូមកុំប្រទូស្តពួកមិត្តឡើយ ព្រោះថាបុគ្គលប្រទូស្តមិត្ត ជាមនុស្សអាក្រក់ ។*

**កុជ្ជំ កិលាសី ភវតិ, យោ មិត្តានិធ ទុព្ភតិ;**
**កាយស្ស ភេទា មិត្តទ្ទុ, និរយំ សោបបជ្ជតិ។**

*បុគ្គលណា ប្រទូស្តមិត្តទាំងឡាយ ក្នុងលោកនេះ បុគ្គលនោះ រមែងកើតឃ្លង់ផង កើតស្រែងផង បុគ្គលអ្នកប្រទូស្តមិត្តនោះ លុះបែកធ្លាយរាងកាយ រមែងទៅកើតក្នុងនរក ។*

*ព្រះសាស្តាត្រាស់អភិសម្ពុទ្ធគាថានេះថា*

**កុជ្ជំ កិលាសី ភវតិ, យោ មិត្តានិធ ទុព្ភតិ;**
**កាយស្ស ភេទា មិត្តទ្ទុ, និរយំ សោបបជ្ជតិ។**

*បុគ្គលណា ប្រទូស្តមិត្តទាំងឡាយ ក្នុងលោកនេះ បុគ្គលនោះ រមែងកើតឃ្លង់ផង កើតស្រែងផង បុគ្គលអ្នកប្រទូស្តមិត្តនោះ លុះបែកធ្លាយរាងកាយ រមែងទៅកើតក្នុងនរក ។*

*អធិប្បាយថា ម្នាលភិក្ខុទាំងឡាយ បុគ្គលណាប្រទូសរ៉ាយបៀតបៀនមិត្ត ក្នុងលោកនេះ បុគ្គលនោះរមែងមានសភាពបែបនោះ ។*

*ផែនដីឲ្យឱកាស បើកជាចន្លោះ ដល់បុរសនោះ ដែលកំពុងនិយាយជាមួយនឹងព្រះរាជា ។ ក្នុងខណៈនោះឯង បុរសនោះក៏ច្យុត ហើយកើតក្នុងអវីចិនរក ។ កាលបុរសនោះចូលទៅកាន់ផែនដីហើយ ព្រះរាជាក៏យាងចេញពីឧទ្យាន ចូលទៅកាន់នគរ ។*

*ព្រះសាស្តានាំព្រះធម្មទេសនានេះមកហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះទេ សូម្បីក្នុងកាលមុន ទេវទត្តប្រមៀលថ្មមកលើតថាគតដែរ ហើយទ្រង់ប្រជុំជាតកថា*

**តទា មិត្តទុព្ភី បុរិសោ ទេវទត្តោ អហោសិ** *បុរសទ្រូស្តមិត្តក្នុងកាលនោះ បានមកជាទេវទត្ត*

**កាបិរាជា បន អហមេវ អហោសិំ** *ចំណែកស្តេចស្វា គឺ តថាគត នេះឯង ។*

*មហាកបិជាតក ចប់។*

*( ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក តឹសនិបាត បិដកលេខ ៦០ ទំព័រ ១៨៧)*

*ថ្ងៃព្រហស្បត៍ ៧ កើត ខែទុតិយាសាឍ ឆ្នាំច សំរិទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០*

*ថ្ងៃទី ១៩ ខែ ឧសភា ព.ស. ២៥៦២ គ.ស.២០១៨*

*ដោយស.ដ.វ.ថ.*